IHSS
IN-HOME SUPPORTIVE SERVICES

CDSS

# ការស្វែងរក ការសម្ភាសន៍ និងការជ្រើសរើសយកអ្នកផ្តល់សេវាមកធ្វើការ

## ការស្វែងរកអ្នកផ្តល់សេវា

ការជ្រើសរើសយកអ្នកផ្តល់សេវាមកធ្វើការគឺជាកិច្ចការសំខាន់ ហើយអ្នកគួរតែចំណាយពេលស្វែងរកមនុស្សដែលសមរម្យ។

ក្នុងនាមជានិយោជក អ្នកអាចជួលនរណាម្នាក់ដែលបំពេញតម្រូវការចុះឈ្មោះជាអ្នកផ្តល់សេវានៃកម្មវិធី IHSS ហើយ អាចបំពេញតាមតម្រូវការរបស់អ្នក។ នេះអាចជាសមាជិកគ្រួសារ មិត្តភ័ក្តិ ឬនរណាម្នាក់ដែលត្រូវបានបញ្ជូនមកពីបញ្ជីចុះឈ្មោះរបស់អាជ្ញាធរសាធារណៈ។ មធ្យោបាយផ្សេងទៀតដើម្បីស្វែងរកអ្នកផ្តល់សេវាអាចតាមរយៈព្រះវិហាររបស់អ្នក ការបិទខិត្តប័ណ្ណនៅលើជញ្ជាំង ឬលើក្តារខៀន ការដាក់ការផ្សាយពាណិជ្ជកម្មនៅក្នុងកាសែតក្នុងតំបន់របស់អ្នក ឬ គ្រាន់តែនិយាយផ្ទាល់មាត់។

សូមចងចាំថាត្រូវប្រុងប្រយ័ត្នចំពោះព័ត៌មានផ្ទាល់ខ្លួន ដែលអ្នកផ្តល់ឱ្យអំពីខ្លួនអ្នកនៅក្នុងដំណើរការនេះ។ កុំដាក់អាសយដ្ឋានផ្ទះរបស់អ្នកនៅលើខិត្តប័ណ្ណ។ ប្រសិនបើអ្នកមិនអាចស្វែងរកអ្នកផ្តល់សេវាបានទេ សូមទាក់ទងទៅការិយាល័យខោនធីផ្នែក IHSS ឬ អាជ្ញាធរសាធារណៈសម្រាប់ជំនួយ។

## ការសម្ភាសន៍អ្នកផ្តល់សេវា

មុនពេលអ្នកសម្ភាសន៍អ្នកផ្តល់សេវា អ្នកគួរតែចំណាយពេលពិនិត្យមើលសេវាកម្មដែលត្រូវបានអនុញ្ញាតសម្រាប់អ្នក និងរយៈពេលប៉ុន្មានដែលត្រូវបានអនុញ្ញាតសំរាប់សេវាកម្មនីមួយៗ ។ ប្រសិនបើអ្នកមានអារម្មណ៍ថាអ្នកផ្តល់សេវាម្នាក់មិនអាចផ្តល់សេវាកម្មទាំងអស់ដែលអ្នកត្រូវការ ឬធ្វើការទាំងអស់នៃម៉ោងដែលមានការអនុញ្ញាតទេ អ្នកអាចចង់ជួលអ្នកផ្តល់សេវាលើសពីមួយនាក់ឡើងទៅ។ ប្រសិនបើអ្នកមានតម្រូវការជាក់លាក់ ដូចជារបបអាហារពិសេស ឬស្វែងរកនរណាម្នាក់ដែលមានសមត្ថភាពក្នុងការលើក ត្រូវប្រាកដថាអ្នកនិយាយអំពីចំណុចនេះក្នុងអំឡុងពេលសម្ភាសន៍។

**អ្នកអាចយល់ថាជំហានវិធានការដែលមានប្រយោជន៍ខាងក្រោម៖**

1. ពិនិត្យជ្រើសរើសអ្នកដាក់ពាក្យស្នើសុំតាមរយៈការសម្ភាសន៍តាមទូរស័ព្ទ។
2. ជួបដោយផ្ទាល់ជាមួយបេក្ខជនដែលមាំមួនរហ័សរហួន។
3. ពិនិត្យឯកសារយោង។

## ការពិនិត្យជ្រើសរើសសម្ភាសន៍តាមទូរស័ព្ទ

ក្នុងអំឡុងពេលការហៅទូរស័ព្ទនេះ អ្នកគួរតែទទួលបានគំនិតល្អអំពីភាពអាចរកបាន បទពិសោធន៍ និងសមត្ថភាពរបស់បុគ្គលនោះក្នុងការអនុវត្តកិច្ចការដែលត្រូវការ។ នេះក៏ជាពេលវេលាដ៏ល្អមួយដើម្បីប្រាប់ពួកគេថាអ្នកផ្តល់សេវា IHSS ត្រូវតែចូលរួមក្នុងវគ្គថ្នាក់ណែនាំបង្ហាញពីរបៀបធ្វើជាអ្នកផ្តល់សេវា ធ្វើការផ្តិតមេដៃ និងឆ្លងផុតដំណើរការនៃការឆែកពិនិត្យសាវតាឧក្រិដ្ឋកម្ម។ ប្រសិនបើអ្នកពេញចិត្តនឹងបុគ្គលនោះ ជំហានបន្ទាប់គឺត្រូវរៀបចំពេលវេលាមួយដើម្បីជួបជាមួយគាត់ ដើម្បីពិភាក្សាអំពីតម្រូវការ និងសេវាកម្មដែលមានការអនុញ្ញាតរបស់អ្នក ហើយស្វែងយល់បន្ថែមអំពីគាត់។

IHSS
IN-HOME
SUPPORTIVE SERVICES

CDSS

## ការសម្ភាសន៍ទល់មុខ

ការសម្ភាសន៍នេះអាចធ្វើឡើងនៅក្នុងផ្ទះរបស់អ្នក ឬនៅកន្លែងសាធារណៈនៅក្បែរនោះ។ ត្រូវពិភាក្សាសុំមិត្តភ័ក្តិ ឬសមាជិកគ្រួសារម្នាក់ឱ្យចូលរួមជាមួយអ្នក ដើម្បីឱ្យពួកគេអាចជួយក្នុងការសម្ភាសន៍ និងជួយសម្រេចចិត្តថាអ្នកណាដែលត្រូវជួលយកមកធ្វើការ។ ប្រសិនបើអាចធ្វើបាន វាជាការល្អក្នុងការសម្ភាសន៍អ្នកដាក់ពាក្យស្នើសុំធ្វើជាអ្នកផ្តល់សេវាឱ្យបានច្រើនជាងម្នាក់។

ធ្វើកំណត់ចំណាំ ក្នុងអំឡុងពេលសម្ភាសន៍ ដែលអ្នកអាចយោងនៅពេលក្រោយ នៅពេលពិនិត្យមើលឯកសារយោង ឬជ្រើសរើសអ្នកណាដែលត្រូវជួលមកធ្វើការ។

នេះជាព័ត៌មានបន្ថែមមួយចំនួនដែលត្រូវនិយាយក្នុងពេលសម្ភាសន៍៖

- សួររកមើលអត្តសញ្ញាណ។ នេះអាចជាប័ណ្ណបើកបររបស់រដ្ឋកាលីហ្វ័រនីញ៉ាដែលមានសុពលភាព ឬអត្តសញ្ញាណប័ណ្ណដែលមានរូបថត។
- ពន្យល់ពីការរំពឹងទុករបស់អ្នកចំពោះការប្រព្រឹត្តក្នុងការងារ រួមទាំងការប្រើប្រាស់របស់របរបស់អ្នក ពេលវេលាមកធ្វើការ និងចេញពីធ្វើការ និងព័ត៌មានផ្សេងទៀតដែលនឹងមានសារៈសំខាន់សម្រាប់ឱ្យបុគ្គលដែលអ្នកជួលបានដឹង។
- និយាយមួយត្រួសពិនិត្យពិច័យអំពីសេវាកម្ម និងម៉ោងដែលបានអនុញ្ញាតសម្រាប់អ្នក។
- សួរថាតើពួកគេធ្លាប់ជាអ្នកផ្តល់សេវា IHSS ពីមុនឬទេ ហើយប្រសិនបើពួកគេបានឆ្លងកាត់ដំណើរការចុះឈ្មោះជាអ្នកផ្តល់សេវា រួមទាំងការផ្តិតមេដៃផងដែរ។
- ផ្តល់ឱកាសឱ្យពួកគេសួរសំណួរទៅអ្នកអំពីការងារ និងសេវាកម្មដែលអ្នកត្រូវការ។

## ការពិនិត្យមើលឯកសារយោង

ការពិនិត្យមើលឯកសារយោងនឹងផ្តល់ឱ្យអ្នកនូវព័ត៌មានដ៏មានតម្លៃអំពីមនុស្សដែលអ្នកកំពុងគិតថានឹងជួលយកមកធ្វើការ។ នៅពេលនិយាយយោងទៅរករបាយការណ៍ សួរសំណួរដែលនឹងផ្តល់ឱ្យអ្នកនូវគំនិតអំពីប្រភេទនៃការងារដែលពួកគេបានធ្វើ រយៈពេលដែលពួកគេត្រូវបានគេជួល ភាពជឿជាក់របស់ពួកគេ និងភាពខ្លាំង និងចំណុចខ្សោយរបស់ពួកគេ។ ត្រូវរក្សាកំណត់ចំណាំអំពីអ្វីដែលឯកសារយោងប្រាប់អ្នក ព្រោះនេះអាចជួយអ្នកក្នុងការសម្រេចចិត្តក្នុងការជ្រើសរើសជួលយកអ្នកណាម្នាក់។

## ការធ្វើសេចក្តីសម្រេចចិត្ត

សូមមើលកំណត់ចំណាំរបស់អ្នក ហើយប្រៀបធៀបភាពខ្លាំង គុណសម្បត្តិ ចំណេះដឹងផ្សេងៗ និងឯកសារយោងរបស់បុគ្គលម្នាក់ៗដែលអ្នកបានសម្ភាសន៍ ហើយសម្រេចចិត្តថាមួយណាដែលសមស្របបំផុតនឹងតម្រូវការរបស់អ្នក។ នៅពេលដែលអ្នកបានធ្វើការសម្រេចចិត្តរបស់អ្នកហើយ សូមប្រាប់ឱ្យបុគ្គលនោះដឹង ហើយបន្ទាប់មកទាក់ទងមកការិយាល័យខោនធីផ្នែក IHSS របស់អ្នក ដើម្បីឱ្យអ្នកផ្តល់សេវារបស់អ្នកអាចចាប់ផ្តើមដំណើរការចុះឈ្មោះ ប្រសិនបើពួកគេមិនទាន់បានធ្វើកិច្ចការនេះនៅឡើយ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យខោនធីផ្នែក IHSS ក្នុងតំបន់របស់អ្នក។**